
រឿង
បក្សីមាស
THE GOLDEN PHOENIX

មានបុរសម្នាក់រស់នៅក្នុងនគរពារាណសី បុរសនោះលុះពេលស្លាប់ទៅៗ កើតជាហង្សមាសមួយនៅក្នុងព្រៃហិមពាន្ត ហង្សមាសនោះចាំជាតិកំណើតរបស់ខ្លួន បានដឹងថា ប្រពន្ធនឹងកូនខ្លួនជួបនូវក្តីក្រីក្រតោកយ៉ាក លំបាកទុគ៌តរកស៊ីដោយការបំរើស៊ីឈ្នួល គេដូច្នោះ ។

There was a man living in Peareanasey Kingdom. When the man died he turned into a phoenix in the Himalayan forest. The bird remembered his previous incarnation and knew that his wife and Children were living in poverty and misery and working for others to earn their living.



ក៏កើតចិត្តអាណិតដល់ប្រពន្ធកូនក្រៃពេក ទើបហើរមកកាន់ផ្ទះប្រពន្ធកូននោះ ហើយនិយាយប្រាប់រឿងរបស់ខ្លួនថា ជាស្វាមីនឹងឪពុកដែលបានស្លាប់ទៅ ហើយៗកើតជា ហង្សមាស ។ ខ្ញុំមកនេះដើម្បីនឹងជំរុះស្លាបមាស១-២ អោយអ្នកនឹងកូនយកទៅលក់ចិញ្ចឹមជីវិត កុំអោយអ្នកនឹងកូនទៅធ្វើការស៊ីឈ្នួលគេទៀត ហង្សប្រាប់សេចក្តីសព្វប្រការ ។

He felt so sorry for his wife and children. Then he flew to their house and told them that he was their father and husband reincarnated into the phoenix. "I came to drop one or two golden feathers, so that you can sell them to earn your living and stop working for others."



ក៏ជំរុះស្លាបមាស១អោយទៅនាងកូនហើយផ្តាំថា បើកូនលក់ស្លាបមាស១នេះចាយអស់កាលណា ចាំយើងមកជំរុះអោយក្នុងកាលនោះទៀត ផ្តាំហើយហង្សមាសក៏លាកូន ប្រពន្ធហើរវិលទៅកាន់លំនៅខ្លួន នៅព្រៃហិមពាន្តវិញហោង ។ ឯនាងប្រពន្ធនឹងកូនទាំងឡាយ ចាប់តាំងពីបានស្លាបហង្សមាសលក់ចាយ ចិញ្ចឹមជីវិតមក ក៏លែងទៅធ្វើការ ស៊ីឈ្នួលគេទៀត ហើយខំសន្សំទ្រព្យធនបានឡើងជាអ្នកមានគ្រាន់បើ ។ ឯហង្សមាសនោះតែងមកជំរុះស្លាបអោយគ្រប់ពេល លុះក្រោយមក នាងប្រពន្ធកើតក្តីលោភលន់ ប្រាថ្នាចង់មានឆាប់ ។

Having said that, he dropped one golden feather to his daughter and told her he would come to drop another when they had spent the money. He then said goodbye to them and flew back to the Himalayan forest. The wife and the children stopped working for other people after they got the golden feather to sell to make their living. They tried to save up and had a decent living, and the phoenix often came to drop feathers. Later, the wife became greedy; she wanted to become rich faster.





ទើបនិយាយនឹងកូនថា " កូនអើយ ! យើងមានប្រាក់ចាយ បាយស៊ី សព្វថ្ងៃនេះ ក៏ព្រោះហង្សជាឪពុកកូនឯង មកជំរុះស្លាបមាសអោយយើងម្តងៗ តើយើងទៅទុកចិត្តសត្វតិរច្ឆាននេះឯណាបាន ។ ប្រសិនបើហង្សមិនមក យើងនឹងបានអ្វីចាយទិញដូរវត្ថុអាស្រ័យតទៅទៀត។ ហេតុនេះម្តាយយល់ថា បើហង្សនោះមកក្នុងថ្ងៃណា យើងនឹងនាំគ្នាចាប់ដកយកស្លាប យករោម អោយអស់រលីង ទុកជាទុនបានច្រើនទៅមុខ តែម្តងកុំអោយមានក្តី ភិតភ័យនឹងក្តីក្រតទៅទៀត "។

She talked to the children, "Children, now we have enough money to make our living because the phoenix who was your father comes to drop feathers once in a while, but how can we trust this bird? If he did not show up, we would have no money to spend. So, when he comes, I think we should catch him and pull out all his feathers to keep them for our future security ."

ឯនាងធីតាទាំងឡាយ ឮម្ដាយបបួលដូច្នោះក៏ហាមម្ដាយថា "ការដែលម៉ែឯងគិត នេះមិនត្រូវទេ យើងជាកូនមិនព្រមធ្វើតាមឡើយ " ។

Having heard her mother's argument, the daughters said, "What you've said is not right. We, the children, will not obey you."





ថ្ងៃមួយសុវណ្ណហង្សមកកាន់ផ្ទះ ដើម្បីនឹងជំរុះស្លាបអោយ ឯនាងព្រាហ្មណី ក៏ស្រដី លួងលោមសំណេះសំណាល នឹងហង្សនោះដោយមាយា ។ បានជិតហង្សកាលណា ក៏ចាប់ហង្សនោះជាប់ ហើយសង្កត់ដកយករោមស្លាបកន្ទុយហង្សនោះទាល់តែ អស់ឥតសល់ ហង្សនោះបានក្តីទុក្ខវេទនាដោយគេដកស្លាបពន់ពេកណាស់ ខំបម្រះ លូនចូលទៅក្នុងទីមានរបាំងដែលអាច បាំងខ្លួននៅបាន ។

One day, the golden phoenix flew to the house to drop its feathers. The wife then enticed him with sweet words. When the bird got closer to her, she caught him and pulled out all the feathers. The bird was badly hurt and struggled to search for a place to hide himself.



ឯរោមស្លាបទាំងឡាយក៏ក្លាយ ជាពណ៌សដូចស្លាបកុកទាំងអស់ មេព្រាហ្មណ៍យកទៅលក់អោយគេក៏ពុំមាននរណាត្រូវការទិញយកឡើយ ។ ឯហង្សនោះទ្រាំទុក្ខវេទនាលុះត្រាតែរោមថ្មីដុះឡើងបានហើយក៏ហើរទៅកាន់ព្រៃហិមពាន្ត ពុំបានមកកាន់ផ្ទះនាងព្រាហ្មណ៍នោះទៀតឡើយ ។

Then all the fur turned into white feathers like those of a crane. She tried to sell them, but no one would ever take them. The bird tried to live on with suffering till the new feathers grew and then he flew to the Himalayan forest. He never returned to his wife's house again.

ចាប់ដើមពីថ្ងៃនោះមក នាងព្រាហ្មណីនោះខាតលាភគឺពុំមានអ្វីលក់ដូរ ចែកចាយដូចកាលថ្ងៃមុនៗនោះទៀតឡើយក៏ធ្លាក់ខ្លួនជាស្រីទុគ៌តវិញហោង ។

From that time on, she had no more luck. She had nothing else to sell. She returned to poverty.

